GMAC

Garment Manufacturers Association in Cambodia

# សេចក្តីប្រកាសព័ត៌មាន

ការនាំចេញផលិតផលធ្វើដំណើររបស់កម្ពុជាមានចំនួនលើស១,២ពាន់លានដុល្លារក្នុងឆ្នាំ២០១៩។

សមាគមរោងចក្រកាត់ដេរនៅកម្ពុជាមានមោទនភាពសូមប្រកាសថា ការនាំចេញផលិតផលធ្វើដំណើររបស់កម្ពុជាទៅពិភពលោកមានចំនួនលើស១,២ពាន់លានដុល្លារក្នុងឆ្នាំ២០១៩ ដោយចាប់ផ្តើមពីកម្រិតទាបខ្លាំងតែប្រហែល៥០លានដុល្លារប៉ុណ្ណោះក្នុងឆ្នាំ២០១៦។ សហរដ្ឋអាមេរិកជាទីផ្សារនាំចេញធំបំផុតរបស់យើងសម្រាប់ផលិតផលនេះដែលមានចំនួនប្រហែល៨០%នៃការនាំចេញសរុប។

កំណើននៃការនាំចេញដ៏សម្បើមនេះ គឺដោយសារកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ក្រសួងពាណិជ្ជកម្មនិងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ក្នុងការដាក់ញត្តិបញ្ចុះបញ្ចូលទៅសភាសហរដ្ឋអាមេរិកដែលនាំឲ្យមានការពិនិត្យប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP)របស់អាមេរិកក្នុងឆ្នាំ២០១៦ ហើយអាមេរិកបានរួមបញ្ចូលមុខទំនិញ ផលិតផលធ្វើដំណើរនៅក្នុងបញ្ជីប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP)។

ក្រឡេកមើលទៅភាពជោគជ័យនៃការនាំចេញនេះ សមាគមសូមថ្លែងអំណរគុណដល់ឯកឧត្តមរដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្មចំពោះការដឹកនាំនិងការគាំទ្ររបស់ឯកឧត្តមក្នុងការធ្វើឲ្យញត្តិនោះទទួលបានជោគជ័យ។ សមាគមក៏សូមថ្លែងអំណរគុណឯកឧត្តមអគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានិងអតីតឯកអគ្គរដ្ឋទូតអាមេរិកចំពោះការគាំទ្រក្នុងការជួយជំរុញបន្ថែមឲ្យមានការវិនិយោគដោយផ្ទាល់ពីបរទេសដោយចូលរួមដំណើរទស្សនកិច្ចជំរុញការវិនិយោគរបស់យើងទៅទីក្រុងហុងកុងក្នុងឆ្នាំ២០១៦។

យើងក៏សូមថ្លែងអំណរគុណអ្នកបញ្ជាទិញទាំងអស់ចំពោះការទិញផលិតផលធ្វើដំណើរពីកម្ពុជានិងទំនុកចិត្តរបស់អតិថិជនប្រើប្រាស់ចុងក្រោយលើផលិតផលធ្វើដំណើរដែលផលិតក្នុងប្រទេសកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

GARMENT MANUFACTURERS



តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Phum Trapeang Kul, Sangkat Kantouk, Khan Por Sen Chey, Phnom Penh, Cambodia.
Tel: (855) 23-301 181 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org